THE SCHOOL DISTRICT OF PHILADELPHIA

ការិយាល័យអគ្គនាយកក្រសួងអប់រំ
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសារទាំងអស់របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

រយៈពេលប៉ុន្មានខែកន្លងមកនេះ បុគ្គលជាច្រើនទូទាំងទីក្រុងមានការមមាញឹកចូលរួមចំណែកក្នុងការអភិវឌ្ឍផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ។ ខណៈពេលដែលនៅមានដំណាក់កាលមួយចំនួនទៀតដែលនៅសេសសល់ ខ្ញុំចង់អបអរសាទរដល់ការបញ្ចប់ដំណាក់កាលសំខាន់ៗពីរ៖ ការកែបន្ថែមបន្ថយនៃបេសកកម្ម ទស្សនៈវិស័យ និង តម្លៃសំខាន់ៗ របស់ក្រសួងអប់រំ និងការបង្កើតទ្រឹស្តីនៃសកម្មភាពទូទាំងក្រសួង។

ក្រុមប្រឹក្សាអប់រំបានកែបន្ថែមបន្ថយនូវបេសកកម្ម ទស្សនៈវិស័យ និងតម្លៃសំខាន់ៗ ដោយប្រើមតិកែលម្អពីក្រុមផែនការយុទ្ធសាស្ត្រទាំងអស់ និងលទ្ធផលដែលបានមកពីការស្ទង់មតិសាធារណៈជន។ ខ្ញុំសូមអរគុណអ្នកដែលបានចំណាយពេលវេលាដើម្បីបំពេញការស្ទង់មតិ និងចែករំលែកការយល់ដឹងរបស់លោកអ្នក។ កំណែដែលបានកែថ្មីៗអាចមើលនៅលើ គេហទំព័រផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ (District’s strategic planning website)។

ដើម្បីដោះស្រាយតម្រូវការសម្រាប់ទ្រឹស្តីនៃសកម្មភាពដែលច្បាស់លាស់ មានទំនាក់ទំនងល្អ ដូចដែលបានរៀបរាប់ក្នុង របាយការណ៍របស់ក្រុមផ្លាស់ប្តូរ (Transition Team Report) យើងបានសហការជាមួយគណៈកម្មាធិការដឹកនាំ ក្រុមដឹកនាំ និងក្រុមប្រឹក្សា ដើម្បីបង្កើតទ្រឹស្តីនៃសកម្មភាពនេះ ដែលជាសេចក្តីថ្លែងការណ៍កម្រិតខ្ពស់អំពីវិធីដែលយើងមានគម្រោងដើម្បីកែលម្អ បង្កើនល្បឿននៃការរីកចម្រើនទៅកាន់គោលដៅរបស់យើង និងជួយសិស្សរៀបចំខ្លួនសម្រាប់អនាគតដែលពួកគេស្រមៃទុក៖

**<u>ទ្រឹស្តីនៃសកម្មភាព</u>**

នៅពេលដែលយើងផ្តោតលើ...

- ការចូលរួមជាមួយក្រុមគ្រួសារ និងសមាជិកសហគមន៍ ក្នុងការអប់រំសិស្សទាំងអស់។
- ការផ្តល់អាទិភាពដល់សុខុមាលភាពនៃសង្គម និងអារម្មណ៍ សុខភាពផ្លូវចិត្ត និងសុវត្ថិភាពប្រាជ្ញា និងរាងកាយ របស់សិស្ស និងបុគ្គលិកទាំងអស់។
- ប្រគល់ឱ្យសាលា និងក្រុមអ្នកដឹកនាំសាលា ជាអង្គភាពនៃការផ្លាស់ប្តូរ។
- ជំរុញឱ្យមានសមធម៌តាមរយៈនៃអ្វីៗគ្រប់យ៉ាងដែលយើងធ្វើ និងរាល់ការសម្រេចចិត្តដែលយើងធ្វើ។ និង

ការិយាល័យអគ្គនាយកក្រសួងអប់រំ
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

- សម្របសម្រួលធនធាន ការហ្វឹកហ្វឺន និងការរៀបចំការទទួលខុសត្រូវ របស់យើង ទៅនឹងការថ្លៃប្រឌិត និងអាទិភាពផ្អែកលើការស្រាវជ្រាវ ដែលមានកម្រិត

បន្ទាប់មកយើងនឹងសម្រេច គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និង ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals and Guardrails) ហើយផ្លាស់ប្តូរការសិក្សា និងលទ្ធផលក្នុងជីវិតសម្រាប់សិស្សទាំងអស់។

ខ្ញុំចង់បញ្ជាក់ថា ការចេញផ្សាយផែនការនេះនៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០២៣ ផែនការយុទ្ធសាស្ត្ររបស់យើង នឹងជាដំណាក់កាលដ៏សំខាន់មួយសម្រាប់ក្រសួងអប់រំ។ ដែលជាទីបញ្ចប់នៃកិច្ចសហប្រតិបត្តិការជាច្រើនខែមកនេះ។ សូមអរគុណចំពោះការចូលរួមក្នុងវគ្គស្តាប់ និងស្វែងយល់ ក្រុមការងារផ្លាស់ប្តូរ និងក្រុមប្រឹក្សាផែនការយុទ្ធសាស្ត្រ – មតិយោបល់របស់លោកអ្នកនឹងផ្តល់ព័ត៌មានសម្រាប់ទិសដៅរបស់ក្រសួងអប់រំសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ។ សូមបន្តចូលទៅកាន់ គេហទំព័រផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ (District's strategic planning website) សម្រាប់ព័ត៌មានថ្មីៗ នៅពេលយើងបន្តដំណើរការនេះ។

ក្នុងភាពជាដៃគូ

Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា